# សេចក្តីសម្រេចដ៏សំខាន់របស់អង្គបុរេជំនុំជម្រះលើទ្រឹស្តី សហឧក្រិដ្ឋកម្មរួមសម្រាប់ការទទួលខុសត្រូវជាបុគ្គល

ដោយ ដេវិត សេហ្វ័រ និង អានថូនី ឌីញ

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០

ប្រែសម្រួលដោយ ទែន សុខស្រីនិត

## សេចក្តីផ្តើម

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានធ្វើការឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមមុខមួយចំនួន ស្តីពីការបែងចែកការទទួលខុសត្រូវរបស់បុគ្គលចំពោះអំពើហិង្សាធ្ងន់ធ្ងរដែលមិនប្រព្រឹត្តឡើងដោយបុគ្គលតែម្នាក់ ពោលគឺប្រព្រឹត្តឡើងជារួម ។ ក្នុងទស្សនៈជាអ្នកបញ្ចេញយោបល់ គោលដៅនៃការអនុវត្តគោលការណ៍ច្បាប់ «ចំពោះស្ថានភាពវឹកវរ និងស្មុគស្មាញនៃជម្លោះប្រដាប់អាវុធ និងអំពើសាហាវយង់ឃ្នងដែលកើតមានឡើងនាពេលបច្ចុប្បន្នគឺជាការតាំងចិត្តដ៏មហិមាមួយដែលមតិខ្លះយល់ឃើញថាកិច្ចខំប្រឹងប្រែងដើម្បីធ្វើឲ្យមានការទទួលខុសត្រូវជាបុគ្គលចំពោះអំពើហិង្សាជាលក្ខណៈប្រវត្តិសាស្ត្រនេះនឹងមិនអាចសម្រេចជាលទ្ធផលបានទេ» ។

ការណែនាំពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួម គឺជាឧទាហរណ៍មួយនៃកិច្ចខំប្រឹងប្រែងជំរុញឲ្យមានការទទួលខុសត្រូវជាបុគ្គលសម្រាប់ឧក្រិដ្ឋកម្មនៃអំពើសាហាវយង់ឃ្នងដ៏ស្មុគស្មាញ (ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរជាដើម) ។ យោងតាមការណែនាំនេះ បុគ្គលម្នាក់មានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងតាមគម្រោងបទ ឧក្រិដ្ឋកម្មរួមមួយ ។ ដើម្បីធ្វើឲ្យបុគ្គលម្នាក់នោះទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមត្រូវតែបង្ហាញឲ្យឃើញថាបុគ្គលនោះបានប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ ។ ការធ្វើដូច្នេះ នឹងធ្វើឲ្យមានការបែងចែកការទទួលខុសត្រូវដល់ជនដែលរួមចំណែកនៅក្នុងការសម្រេចផែនការឧក្រិដ្ឋមួយ ប៉ុន្តែក្នុងករណីដែលជននោះមិនបានប្រព្រឹត្តការសម្លាប់ ធ្វើទារុណកម្ម និងការរំលោភលើមនុស្សរាប់លាននាក់នោះទេ ។ ដូច្នេះ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមផ្តល់ជាមធ្យោបាយមួយដើម្បីធ្វើការបែងចែកការទទួលខុសត្រូវដល់មេដឹកនាំជាន់ខ្ពស់ដែលមិនមែនជាជនប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ ប៉ុន្តែជាជនដែលមានពិរុទ្ធភាពខ្ពស់សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចថា ការណែនាំពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនឹងយកមកអនុវត្តចំពោះមុខ អ.វ.ត.ក (សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ) ។ សេចក្តី

សម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជាសេចក្តីសម្រេចដ៏មានសារៈសំខាន់ដែលមិនដែលធ្លាប់ពីមុនមកនៅ អ.វ.ត.ក ។ សេចក្តីសម្រេចនេះធ្វើឡើងជាកិច្ចឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទបីរូប ដែលប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រាប់ការអនុម័តទ្រឹស្តីប្រភេទទាំងបីនៃសហឧក្រិដ្ឋកម្មរួម ។ នៅក្នុងការពន្យល់បកស្រាយទ្រឹស្តីនេះ ទ្រឹស្តីប្រភេទទីមួយ(ទម្រង់មូលដ្ឋាន) គឺយកទៅអនុវត្តលើក្រុមបុគ្គលដែលមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មរួម ដែលធ្វើឡើងស្របទៅតាមផែនការរួម ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម ។ លក្ខណៈនៃប្រភេទទីមួយនេះ គឺថាអ្នកចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់មានគោលដៅរួមដូចគ្នាមួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ទ្រឹស្តីប្រភេទទីពីរនៃសហឧក្រិដ្ឋកម្មរួម (ទម្រង់ប្រព័ន្ធ) គឺធ្វើឲ្យជនណាម្នាក់ទទួលខុសត្រូវសម្រាប់ការចូលរួមនៅក្នុងគម្រោងរបស់ស្ថាប័នណាមួយ ដូចជាជំរុំប្រមូលផ្តុំដែលនៅទីនោះផែនការប្រព្រឹត្តឧក្រិដ្ឋកម្មត្រូវបានរៀបចំឡើង ។ ទ្រឹស្តីប្រភេទទីបី នៃសហឧក្រិដ្ឋកម្មរួម (ទម្រង់ទូលាយ) គឺធ្វើការចោទប្រកាន់ជនណាម្នាក់ពីបទឧក្រិដ្ឋកម្មដែលមិនមែនជាផ្នែករបស់ផែនការរួម ប៉ុន្តែបង្កជាដំណើរការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានមើលឃើញជាក់ស្តែង ។

អង្គបុរេជំនុំជម្រះបានសម្រេចថាប្រភេទទីមួយ និងប្រភេទទីពីរនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺជាច្បាប់ទម្លាប់អន្តរជាតិ ហើយអាចយកមកអនុវត្តបានចំពោះមុខ អ.វ.ត.ក បាន ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានសម្រេចមិនអនុម័តប្រភេទទីបីនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះទេ ។

## ដំណើរឆ្ពោះទៅរកការជំទាស់តិច ឬដំណើរឆ្ពោះទៅរកការជំទាស់ច្រើន?

អ្នកបញ្ចេញយោបល់នៅលើគេហទំព័រនេះម្នាក់បានអះអាងថា “ដំណើរឆ្ពោះទៅរកការជំទាស់ផ្នែកនយោបាយបាយតិច” គឺជាហេតុផលមួយដែលអង្គបុរេជំនុំជម្រះគួរតែអនុម័តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះ ។ វាជាការពិតដែលទ្រឹស្តីសហឧក្រិដ្ឋកម្មនេះ ត្រូវបានអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សម្រាប់រ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដើម្បីដោះស្រាយឧក្រិដ្ឋកម្មអំពើសាហាវយង់ឃ្នងដែលកើតមានតាមសហគមន៍នីមួយៗ ។

យ៉ាងណាមិញ ការអនុវត្តនេះធ្វើការជំទាស់នឹងទិន្នាការប្រឆាំងនឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមកាលពីថ្មីៗនេះ ។ សេចក្តីជំទាស់នឹងការអនុម័តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមលើកចុងក្រោយត្រូវបានធ្វើឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅទីនោះអង្គបុរេជំនុំជម្រះបានច្រានចោលទ្រឹស្តីសហឧក្រិដ្ឋកម្មនេះ បើទោះបីជាមានការជិតទទួលស្គាល់ពីតុលាការពិសេសដែលអនុវត្តច្បាប់ទម្លាប់អន្តរជាតិក៏ដោយ ។ នៅឯតុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវីវិញ ខណៈពេលដែលការអនុវត្តនៃទ្រឹស្តីនេះត្រូវបានយល់ស្របតាមផ្លូវច្បាប់នោះ នៅក្នុងរឿងក្តីរបស់ Stakic អង្គជំនុំជម្រះបានច្រានចោលទ្រឹស្តីនៃសហ

ឧក្រិដ្ឋកម្មរួមថា មិនមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ សេចក្ដីសម្រេចទាំងអស់នេះត្រូវបានធ្វើឡើងស្របពេលដែលមានមតិរិះគន់ពីទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួម ចាប់តាំងពីពេលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានអនុវត្តទ្រឹស្ដីទាំងអស់នេះមុនដំបូងគេ ។ ចំណែកឯ នៅ អ.វ.ត.ក វិញ ចៅក្រមអង្គបុរេជំនុំជម្រះហាក់បីដូចជាពិបាកក្នុងការសម្រេចចិត្តថាតើគួរតែអនុវត្តទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួមឬយ៉ាងណា ។ ចៅក្រមធ្លាប់បានគេចវេះពីបញ្ហានេះម្ដង នៅពេលដែលមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង ឌុច ហើយបានសុំជំនួយពីអ្នកប្រឹក្សាយោបល់ទាក់ទិននឹងបញ្ហានេះ ។

ការពិភាក្សាវែកញែកពីទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួម បានក្លាយជាប្រជាមតិស្ដីពីធម្មានុរូបនៃច្បាប់ដែលត្រូវយកមកអនុវត្តនៅតុលាការពិសេសទាំងអស់នេះ ។ នេះគឺជាបញ្ហាដ៏លំបាកមួយសម្រាប់តុលាការទាំងអស់ រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដែលទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មនេះត្រូវបានបង្កើតឡើងយ៉ាងហ្មត់ចត់ ។ ដោយសារតែ អ.វ.ត.ក ត្រូវបានចោទប្រកាន់ពីបញ្ហាពុករលួយ និងភាពលំអៀងចាប់តាំងពីដំណើរការដំបូងរបស់ខ្លួន នោះទស្សនៈដែលថាតុលាការកំពុងតែអនុវត្តគោលការណ៍ច្បាប់មិនច្បាស់លាស់អាចនឹងបង្កជាបញ្ហានយោបាយដល់ អ.វ.ត.ក ។ ដូច្នេះ និន្នាការថ្មីប្រឆាំងនឹងទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួមនេះឆ្លុះបញ្ចាំងឲ្យឃើញថា ដើម្បីឲ្យមានការជំទាស់តិចតួច អង្គបុរេជំនុំជម្រះគួរតែមិនអនុវត្តទ្រឹស្ដីនៃសហឧក្រិដកម្មរួមនេះទេ ។

## ការត្រួតពិនិត្យសាឡើងវិញដ៏យូរមួយ : សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះធ្វើការពិនិត្យសាឡើងវិញលើយុត្តិសាស្ត្រមូលដ្ឋានរបស់ទ្រឹស្ដីសហឧក្រិដ្ឋកម្មរួម

នៅក្នុងសេចក្ដីសម្រេចកាលពីថ្ងៃទី២០ ខែឧសភា អង្គបុរេជំនុំជម្រះបានផ្ដល់ជាការពិនិត្យសាឡើងវិញដ៏លម្អិតបំផុតលើប្រវត្តិ និងយុត្តិសាស្ត្រមូលដ្ឋានរបស់ទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមចាប់តាំងពីមានសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់រឿងក្ដី Tadic ។ បើទោះបីជាតុលាការពិសេសជាច្រើន បានអនុម័តទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមយ៉ាងទូលំទូលាយក៏ដោយ ក៏តុលាការទាំងអស់នេះបានពឹងផ្អែកលើការវិភាគរបស់តុលាការ Tadic ស្ទើរតែទាំងស្រុង ។ ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា និងតុលាការពិសេសសម្រាប់ សៀរ៉ាឡេអូន មិនបានពិនិត្យសាឡើងវិញលើយុត្តិសាស្ត្រដែលតុលាការ Tadic ផ្អែកលើនោះទេ ។ តុលាការទាំងនេះបានអនុម័តតាមសេចក្ដីសម្រេចរបស់តុលាការ Tadic នេះទាំងស្រុងដោយជឿជាក់លើកត្ដាដែលថាតុលាការទាំងអស់នេះបានប្រឈមមុខនឹងបញ្ហាដូចគ្នា ដែលធ្លាប់កើតមាននៅក្នុងតុលាការ Tadic ពីមុនមក និងដោយភាពងាយស្រួលក្នុងការយកគំរូតាមល័ក្ខ

ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ កត្តានេះ បានធ្វើឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ាន់ដា និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន មិនចាំបាច់សម្រេចថា តើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺជាច្បាប់ទម្លាប់អន្តរជាតិនោះទេ ខណៈពេលដែលព្រឹត្តិការណ៍នេះបានកើតឡើងនៅក្នុងតុលាការទាំងពីរ ហើយមិនចាំបាច់សម្រេចថាតើលក្ខន្តិកៈគ្រប់គ្រងរបស់ខ្លួនអនុញ្ញាតឲ្យមានការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មនោះទេ ។

ហេតុការណ៍ដែលកើតមានចំពោះមុខ អ.វ.ត.ក នាពេលនេះឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាប្រឈមមុខដែលធ្លាប់បានកើតឡើងនៅយូហ្គោស្លាវី កាលពីពីរទសវត្សរ៍មុន ។ ដូច្នេះយើងឃើញថាបញ្ហានេះគឺឋិតនៅក្រៅវិសាលភាពរបស់តុលាការ Tadic ។ បន្ថែមលើនេះ លក្ខណៈកូនកាត់របស់ អ.វ.ត.ក បានបង្ហាញឲ្យឃើញពីបញ្ហាប្រឈមមុខបន្ថែមទៀតក្នុងការសម្របសម្រួលច្បាប់កម្ពុជា និងច្បាប់អន្តរជាតិសម្រាប់ អ.វ.ត.ក ។ អង្គបុរេជំនុំជម្រះត្រូវបានជំរុញឲ្យធ្វើការពិនិត្យមើលមូលដ្ឋានដើម de novo ដើម្បីទទួលស្គាល់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម និងគួរតែកំណត់យកយុត្តិសាស្ត្រណាមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ។ ដូច្នេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះរួមមាន ការពិនិត្យដ៏លម្អិតលើលក្ខន្តិកៈក្រោយសង្គ្រាមលោកលើកទី២ដែលបង្កើតឡើងសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិដំបូង ច្បាប់ករណីរបស់តុលាការដែលអនុលោមទៅតាមលក្ខន្តិកៈទាំងអស់នេះ កិច្ចការរបស់គណៈកម្មាការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិដែលតំណាងឲ្យការអនុវត្តរបស់សហគមន៍អន្តរជាតិ និងការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា និងប្រទេសដែលពាក់ព័ន្ធផ្សេងទៀតកាលពីឆ្នាំ១៩៧៥ ។

យោងតាមការពិនិត្យនេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមានលក្ខណៈស៊ីជម្រៅជាងសេចក្តីសម្រេចរបស់តុលាការ Tadic និងធ្វើការបកស្រាយបញ្ហាដែលតុលាការ Tadic មិនបានលើកឡើង ។ អង្គបុរេជំនុំជម្រះបានសម្រេចថាគោលការណ៍សំខាន់នៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួមបានក្លាយជាច្បាប់ទម្លាប់ទៅហើយ នៅក្នុងច្បាប់អន្តរជាតិចាប់តាំងពីទសវត្សរ៍ទី៤០មកម្ល៉េះ ។ លើសពីនេះ លក្ខណៈវិនិច្ឆ័យសម្រាប់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ក៏បញ្ជាក់ថាតុលាការមិនចាំបាច់ពិចារណាលើកត្តាដែលហួសពីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ដើម្បីសម្រេចថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួម គឺជាច្បាប់ទម្លាប់អន្តរជាតិនោះទេ ។ អង្គបុរេជំនុំជម្រះបានសម្រេចថាខ្លួនមិនចាំបាច់ពិចារណាពីសេចក្តីព្រាងលក្ខន្តិកៈក្រុងរ៉ូម និងអនុសញ្ញាអន្តរជាតិសម្រាប់ការបង្ក្រាបភេរវកម្មទម្លាក់គ្រាប់បែកដែលតុលាការ Tadic បានផ្អែកលើដែលទទួលការរិះគន់នោះទេ ។ អង្គបុរេជំនុំជម្រះបានយោងសេចក្តីសម្រេចរបស់ខ្លួនដោយផ្អែកលើល័ក្ខខន្តិកៈគ្រប់គ្រងតុលាការក្រោយសង្គ្រាមលោកលើកទី២ និងច្បាប់ករណីរបស់តុលាការទាំងនេះ ។ អង្គបុរេជំនុំជម្រះបានសម្រេចថាយុត្តិសាស្ត្រនេះមានលក្ខណៈគ្រប់គ្រាន់ក្នុងការចាត់

ទុកទ្រឹស្តីនៃសហឧក្រិដ្ឋកម្មជាច្បាប់ទម្លាប់អន្តរជាតិ និងជាទ្រឹស្តីសហឧក្រិដ្ឋកម្មដ៏មានប្រសិទ្ធភាពសម្រាប់អង្គបុរេជំនុំជម្រះចាប់តាំងពីទសវត្សរ៍ទី៤០មក ។

## **អង្គបុរេជំនុំជម្រះបានបកស្រាយទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ខុស**

យ៉ាងណាមិញ អង្គបុរេជំនុំជម្រះបានបកស្រាយទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ខុស ។ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣គឺជាប្រភេទដែលពិបាកបកស្រាយបំផុត ។ ទ្រឹស្តីប្រភេទនេះគឺធ្វើឲ្យជនណាម្នាក់មានការទទួលខុសត្រូវសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រយោលដែលមិនបានគ្រោងទុកជាមុន ប៉ុន្តែបានកើតឡើងនៅពេលដែលជននោះបានបង្កើតផែនការឧក្រិដ្ឋកម្មខ្លួនឯង ។ ឧក្រិដ្ឋកម្មទាំងនោះត្រូវតែបានមើលឃើញហើយមានលក្ខណៈស្រដៀងគ្នានឹងចេតនាឧក្រិដ្ឋដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌក្នុងស្រុក ។ តុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសផ្សេងទៀតបានសម្រេចទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣គឺជាច្បាប់ទម្លាប់អន្តរជាតិ ហើយវាគឺជាប្រភេទមួយដែលផ្តោតការយកចិត្តទុកដាក់នៅពេលដែលតុលាការ Tadic បានទទួលស្គាល់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមជាច្បាប់ទំនៀមទម្លាប់ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការមិនទទួលយកទ្រឹស្តីសហឧក្រិដ្ឋកម្មប្រភេទទី៣ គឺបណ្តាលមកពីការអាក់ខានមិនបានពិចារណាលើអនុសញ្ញាច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលពាក់ព័ន្ធ និងការយល់ឃើញរបស់តុលាការពីលក្ខណៈខុសប្លែកគ្នាមិនច្បាស់លាស់ នៅក្នុងយុត្តិសាស្ត្រកំណត់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ ។ អង្គបុរេជំនុំជម្រះមិនបានធ្វើការបដិសេធទទួលអនុវត្តប្រភេទទីបីភ្លាមដូចតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ។ ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះបានចេញការបដិសេធស្តីពីឯកសារយោងដែលមានលក្ខណៈច្បាស់លាស់ និងមិនច្បាស់លាស់ ។ ដំបូងអង្គបុរេជំនុំជម្រះនៅ អ.វ.ត.ក បានកត់សម្គាល់ថា ច្បាប់ករណីក្រោយសង្គ្រាមលោកលើកទី២ «មានជាប់ពាក់ព័ន្ធនឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣» ។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថាហេតុផល និងការវិនិច្ឆ័យរបស់តុលាការក្រោយសង្គ្រាមលោកលើកទី២មានលក្ខណៈស្របទៅតាមការអនុវត្តរបស់ទ្រឹស្តីប្រភេទទីបីនេះ ប៉ុន្តែ អង្គជំនុំជម្រះបានបដិសេធមិនទទួលយកទ្រឹស្តីនេះមកអនុវត្ត ពីព្រោះអង្គបុរេជំនុំជម្រះយល់ថា ដោយសារតែកង្វះខាតខាងកំណត់ត្រារបស់តុលាការ ទើបអង្គបុរេជំនុំជម្រះមិន«ច្បាស់លាស់»ថា ច្បាប់ករណីទាំងអស់នេះ អាចយកមកអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣បានបុយ៉ាងណា ។ ជាមួយគ្នានេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថាធម្មនុញ្ញរបស់តុលាការ ណូរឹមប៊ឺក និងច្បាប់ក្រុមប្រឹក្សាសន្តិសុខ

ទី១០ មិនបានផ្តល់ជាការគាំទ្រឲ្យបានជាក់លាក់សម្រាប់ទម្រង់ទូលាយនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះទេ ។

បញ្ហាដំបូង អង្គបុរេជំនុំជម្រះធ្វើការពិចារណាលើល័ក្ខខន្តិកៈព្រហ្មទណ្ឌអន្តរជាតិសំខាន់មួយដែលជាផ្នែកមួយនៃអង្គជំនុំជម្រះរបស់តុលាការក្រោយសង្គ្រាមលោកលើកទី២ ។ អង្គបុរេជំនុំជម្រះខកខានមិនបានធ្វើការពិចារណាច្បាប់ធម្មនុញ្ញទីក្រុងតូក្យូ ដែលយកមកអនុវត្តនៅតុលាការសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមនៅអាស៊ី ។ តុលាការសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមនេះបានធ្វើការវិនិច្ឆ័យទោសទាំងឧក្រិដ្ឋកម្មក្នុងស្រុកនិងឧក្រិដ្ឋកម្មអន្តរជាតិនៅអាស៊ី ហើយបានដំណើរការស្របជាមួយនឹងតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅអឺរ៉ុប ។ មាត្រា៥(គ)នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (ធម្មនុញ្ញរបស់ទីក្រុងតូក្យូ) ចែងថា :

*“មេដឹកនាំ អ្នករៀបចំគ្រោងការណ៍ អ្នកមេគំនិត និងអ្នកសមគំនិតដែលចូលរួមនៅក្នុងការរៀបចំគម្រោង ឬផែនការសម្ងាប់រួម ឬគម្រោងការណ៍សម្ងាត់ទាំងអស់ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម ត្រូវតែទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់នេះ ដែលប្រព្រឹត្តឡើងដោយជនណាម្នាក់នៅក្នុងគម្រោងសម្ងាប់នោះ” ។*

សេចក្តីចែងខាងលើរបស់ធម្មនុញ្ញតូក្យូនេះផ្តល់ការគាំទ្រជាលាយល័ក្ខអក្សរយ៉ាងច្បាស់ និងជាក់លាក់ស្តីពីការទទួលខុសត្រូវនៃទ្រឹស្តីប្រភេទទី៣នៃសហឧក្រិដ្ឋកម្មរួម ដល់តុលាការកាត់ទោសព្រហ្មទណ្ឌអន្តរជាតិ ។ ដោយមិនបានពិចារណាពីធម្មនុញ្ញនេះ អង្គបុរេជំនុំជម្រះអាក់ខានមិនបានពិចារណាពីធនធានសំខាន់មួយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬផ្តល់មូលហេតុដ៏សមហេតុផលសម្រាប់ការច្រានចោលនូវធម្មនុញ្ញទីក្រុងតូក្យូ ស្របពេលដែលអង្គបុរេជំនុំជម្រះផ្តល់ការគោរពដល់ធម្មនុញ្ញរបស់ប្រទេសអឺរ៉ុប ។

ទាក់ទងនឹងយុត្តិសាស្ត្ររបស់តុលាការក្រោយសង្គ្រាមលោកលើកទី២ តុលាការមិនបានវិនិច្ឆ័យអង្គហេតុនៃរឿងក្តីដែលពាក់ព័ន្ធនឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ទេ ។ អង្គបុរេជំនុំជម្រះបានធ្វើសេចក្តីយោងតាមភាសាដែលប្រើប្រាស់សម្រាប់តុលាការ Tadic ដើម្បីអះអាងថាភាពមិនច្បាស់លាស់បានកើតមានឡើង ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះមិនបានពិចារណាករណីរឿងក្តីរបស់ Borkum Island និង Essen Lynching ឡើយ ។ រឿងក្តីទាំងពីរនេះមិនរាប់បញ្ចូលការកាត់ទោសជាផ្លូវការរបស់តុលាការទេ ប៉ុន្តែ រឿងក្តីនេះធ្វើការដាក់បញ្ចូលកំណត់ត្រារបស់អង្គហេតុ ភស្តុតាង និងលទ្ធផលសម្រេចបាន ។ បើទោះបីជា“ភាពច្បាស់លាស់”គឺត្រូវតែធ្វើជាសេចក្តីយោងក៏ដោយ ក៏វាជាការយល់ខុសក្នុងការនិយាយថា ភាពច្បាស់លាស់គឺជាបទដ្ឋានដែលតុលាការតម្រូវឲ្យគោរពតាមខណៈពេលដែលអនុវត្តតាមយុត្តិសាស្ត្រពាក់ព័ន្ធ ។ អង្គហេតុ និងការវិនិច្ឆ័យទោសនៅក្នុងរឿងក្តី Borkum និង Essen ផ្តល់

ជាសេចក្តីយោងដ៏ច្បាស់លាស់ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលជនជាប់ចោទមិនមានបំណងជាក់លាក់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ ប៉ុន្តែឧក្រិដ្ឋកម្មនេះ កើតចេញពីសកម្មភាពរបស់ជនជាប់ចោទនៅក្នុងការចូលរួមផែនការឧក្រិដ្ឋកម្មរួមមួយ ។ នៅក្នុងរឿងក្តីរបស់ Borkum និង Essen គ្មានភស្តុតាងណាមួយចោទថាជនជាប់ចោទមានបំណងជាក់លាក់ក្នុងការ សម្លាប់ជនរងគ្រោះនោះទេ ។ ប៉ុន្តែ តុលាការដាក់ទណ្ឌកម្មកម្រិតធ្ងន់ធ្ងរ (ដូចជាទោសប្រហារជីវិតដោយព្យួរក) ចេញពីរឿងក្តីនេះសម្រាប់ជនជាប់ចោទដែលមិនបានប្រព្រឹត្តការសម្លាប់ដោយផ្ទាល់ដៃ ប៉ុន្តែជាជនដែលចូលរួមដឹកនាំផែនការឧក្រិដ្ឋកម្មរួម ដើម្បីធ្វើបាបជនរងគ្រោះ ។

បន្ថែមលើនេះ វាមិនទាន់ច្បាស់លាស់នៅឡើយទេថា តើយុត្តិសាស្រ្តខាងលើមានទាក់ទិននឹងសេចក្តីយោងផ្សេងពីយុត្តិសាស្រ្តក្រោយសង្រ្គាមលោកលើកទី២ ដែលជំរុញឲ្យអង្គបុរេជំនុំជម្រះយល់ឃើញ«ដោយគ្មានចម្ងល់»ថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី១ និងទី២គឺជាច្បាប់ទម្លាប់អន្តរជាតិ ។ ដូចគ្នានឹងរឿងក្តីទាំងពីរខាងលើ មូលដ្ឋាននៃទ្រឹស្តីសហឧក្រិដ្ឋកម្មប្រភេទទី២មានទាក់ទិននឹងករណីចំនួនពីរ ។ លើសពីនេះ ករណីជាច្រើនសម្រាប់ទ្រឹស្តីសហឧក្រិដ្ឋកម្មប្រភេទទី១ និងទី២ មិនមានជាកំណត់ត្រាជាក់លាក់ពីសេចក្តីសម្រេចរបស់តុលាការទេ ប៉ុន្តែវាគ្រាន់តែជាសេចក្តីសង្ខេបជារួមដោយចៅក្រមផ្សេងៗតែប៉ុណ្ណោះ ។ ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះសោកស្តាយចំពោះការខ្វះខាតនូវសេចក្តីយោងសម្រាប់ទ្រឹស្តីសហឧក្រិដ្ឋកម្មប្រភេទទី៣នៅតុលាការយោធាអន្តរជាតិ និងច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រងទាំង១០ ប៉ុន្តែវាក៏គ្មានការលើកឡើងពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ដែរ ។ លើសពីនេះ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី២ ក៏មិនមានភាពជាប់ពាក់ព័ន្ធគ្នាស្រដៀងគ្នានឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ដែលស្តីពីគោលបំណងរបស់ជនដែលដល់ក្នុងការចូលរួមជំរុំប្រមូលផ្តុំ និងមូលហេតុជាក់លាក់ថាតើជនដែលដល់ពិតជាមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងជំរុំនោះដែរ ។ ដូច្នេះ គោលបំណងរបស់អង្គបុរេជំនុំជម្រះ ក្នុងការបែកឲ្យដាច់ដោយឡែករវាងយុត្តិសាស្រ្តរបស់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី១ និងទី២ជាមួយនឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣មានលក្ខណៈមិនច្បាស់លាស់ឡើយ ។ បើទោះបីជាអង្គជំនុំជម្រះសម្រេចថាទ្រឹស្តីសហឧក្រិដ្ឋកម្មប្រភេទទី១ និងទី២ជាច្បាប់ទំនៀមទម្លាប់ «ដោយគ្មានចម្ងល់»ក៏ដោយ ក៏យុត្តិសាស្រ្តដែលបណ្តាលឲ្យតុលាការសម្រេចដូច្នេះបានតម្រូវឲ្យមានសេចក្តីយោងស្តីពីលក្ខណៈខុសប្លែកគ្នាបន្តិចបន្តួចដូចដែលមាននៅក្នុងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី ៣ ។

## ការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមជួយវិវត្តគោលដៅចម្បងរបស់ អ.វ.ត.ក និងយុត្តិធម៌ ព្រហ្មទណ្ឌអន្តរជាតិ

លើសពីការកំណត់ថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួមជាច្បាប់ទំនៀមទម្លាប់ អង្គបុរេជំនុំជម្រះក៏មានកាតព្វកិច្ចសម្រេចថាតើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមអាចយកមកអនុវត្តតាមគោលដៅចម្បងរបស់ អ.វ.ត.ក បានឬយ៉ាងណា ។ មាត្រា២នៃច្បាប់ អ.វ.ត.ក និងមាត្រា១នៃកិច្ចព្រមព្រៀងបានកំណត់គោលដៅរបស់តុលាការ ។ ច្បាប់ អ.វ.ត.ក ចែងថា ៖

មាត្រា២ ៖ «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង...... ដើម្បីនាំមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់មកជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

កិច្ចព្រមព្រៀងចែងថា ៖

មាត្រា១ ៖ «គោលបំណងរបស់កិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា...» ។

យោងតាមឯកសារខាងលើនេះ គោលដៅរបស់ អ.វ.ត.ក មានពីរ គឺ ៖ ទីមួយគឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥រហូតដល់១៩៧៩ ។ ទីពីរគឺដើម្បីដាក់ឲ្យបុគ្គលទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនបានចូលរួម ។ គោលបំណងចម្បងរបស់អ្នកចេញសេចក្តីព្រាងរបស់ អ.វ.ត.ក ដើម្បីពង្រឹង«ការទទួលបាននូវយុត្តិធម៌ ការផ្សះផ្សាជាតិ ស្ថេរភាពសន្តិភាព និងសុវត្ថិភាពគឺជាគោលដៅបន្ទាប់បន្សំ ។ គោលដៅទាំងអស់នេះមានលក្ខណៈដូចគ្នានឹងគោលដៅដែលបានពិភាក្សានៅក្នុងអង្គសភាជាតិនៅក្នុងអំឡុងពេលព្រាងច្បាប់ អ.វ.ត.ក ។

អ្នកចេញសេចក្តីព្រាងដែលក្នុងនោះរួមមាន លោកសាស្ត្រាចារ្យ ដេវិត សេហ្វ័រ មិនបានពិចារណាមើលទ្រឹស្តីសហឧក្រិដ្ឋកម្មរួមជាពិសេសនោះទេ ។ ពោលគឺ គ្មានការលើកឡើងពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ អ.វ.ត.ក ឬកិច្ចព្រមព្រៀងឡើយ ។ យ៉ាងណាមិញ គោលបំណងរបស់តុលាការក្នុងការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុស

ត្រូវខ្ពស់បញ្ជាក់ឲ្យឃើញថាទ្រឹស្តីសហឧក្រិដ្ឋកម្មរួមអាចយកមកអនុវត្តសម្រាប់ការកាត់សេចក្តីនៅចំពោះ អ.វ.ត.ក បាន ។ យុត្តិសាស្ត្រដោយឡែករបស់តុលាការផ្ទាល់សន្មតថាជនជាប់ចោទត្រូវបានតែងតាំងឡើងនៅក្នុងអង្គភាពរួមមួយដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងតាមរយៈប្រព័ន្ធតាក់តែងនេះ ។ តាមរយៈការជ្រើសយកតែមេដឹកនាំមកកាត់ទោស ច្បាប់អនុវត្តមិនអនុញ្ញាតឲ្យមានការកាត់ទោសជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនោះទេ ។ សេចក្តីថ្លែងការជាសាធារណៈរបស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាព្រមទាំងការជជែកពិភាក្សានៅក្នុងរាជសភាជាតិកម្ពុជា ឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកចេញសេចក្តីព្រាងសម្រេចថា មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលមានឥទ្ធិពលនៅក្នុងអង្គភាពណាមួយនោះមានពិរុទ្ធភាពចំពោះការរំលោភច្បាប់ដែលត្រូវបានប្រព្រឹត្តឡើង ។ ដូច្នេះ ដើម្បីធ្វើការកាត់សេចក្តីជនសង្ស័យឲ្យបានគ្រប់ជ្រុងជ្រោយ ចំពោះពិរុទ្ធភាពដែលអ្នកចេញសេចក្តីព្រាងបានគិតទុកមុននោះ តុលាការត្រូវតែកាត់ទោសជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងលក្ខណៈសហឧក្រិដ្ឋកម្មរួម ។

លក្ខណៈនៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់របស់ អ.វ.ត.ក មិនអាចឆ្លុះបញ្ចាំងឲ្យឃើញពិរុទ្ធភាពដែលមាននៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាលក្ខណៈរួមទេ ។ ផ្ទុយទៅវិញ ពិរុទ្ធភាពដែលត្រូវបានពិចារណានៅក្នុងច្បាប់ អ.វ.ត.ក មានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមវិញទេ ។ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមពិចារណាលើការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតឡើងដោយការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ។ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមទទួលស្គាល់ថាជនទាំងឡាយ ដែលចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មប៉ុន្តែមិនមែនជាកត្តាបង្កឲ្យមានឧក្រិដ្ឋកម្មនោះក៏អាចមានពិរុទ្ធភាព ឬមានពិរុទ្ធភាពខ្លាំងជាងជនដៃដល់ផ្ទាល់ ។ ការទទួលស្គាល់នេះមានលក្ខណៈស្របគ្នានឹងគោលបំណង និងគោលដៅរបស់ អ.វ.ត.ក ក្នុងការធ្វើឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវផ្ទាល់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយណាដែលខ្លួនបានចូលរួម ។ ប្រសិនបើគ្មានទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នោះតុលាការមិនអាចកាត់ទោសជនដៃដល់ទៅតាមកម្រិតពិរុទ្ធភាព យោងទៅតាមសកម្មភាពឧក្រិដ្ឋកម្មរបស់ជននោះបានទេ ។ ដូច្នេះ មានតែតាមរយៈការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះទេ ទើបតុលាការអាចសម្រេចគោលបំណង និងគោលដៅរបស់ អ.វ.ត.ក បាន ។

បន្ថែមលើនេះ ពាក្យពេចន៍ដែលសរសេរនៅក្នុងមាត្រា៣-៨នៃច្បាប់ អ.វ.ត.ក ដែលបានបង្កើតឡើងសម្រាប់ឧក្រិដ្ឋកម្មសំខាន់ក្រោមឆន្ទានុសិទ្ធិរបស់តុលាការក៏ធ្វើការឆ្លុះបញ្ចាំងឲ្យឃើញថាតុលាការត្រូវតែពិចារណាពីទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ។ មាត្រា៣-៦ចែងថា គោលដៅរបស់តុលាការ គឺដើម្បីកាត់ទោស “*ជនសង្ស័យទាំងអស់*” ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុង

ហ្សីណែរ ។ មាត្រា៧-៨ចែងថាតុលាការត្រូវតែធ្វើការកាត់ទោស "ជនសង្ស័យដែលទទួលខុសត្រូវខ្ពស់ទាំងអស់" សម្រាប់ការបំផ្លិចបំផ្លាញកេរ្តិ៍តំណែលវប្បធម៌ និងឧក្រិដ្ឋកម្មប្រព្រឹត្តចំពោះជនដែលត្រូវបានការពារជាអន្តរជាតិ ។ បើទោះបីជាលក្ខន្តិកៈកំណត់ឆន្ទានុសិទ្ធិផ្ទាល់របស់តុលាការឲ្យធ្វើការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់ក៏ដោយ ក៏ជនសង្ស័យទាំងអស់នេះប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈផែនការឧក្រិដ្ឋកម្មរួមក៏ថាបាន ។ ដូច្នេះ ដើម្បីឲ្យ អ.វ.ត.ក សម្រេចការងារទៅតាមគោលនយោបាយរបស់ខ្លួននោះ តុលាការពិតជាមានភារកិច្ចចាំបាច់ក្នុងការកាត់ទោសជនសង្ស័យទាំងអស់នេះដោយមិនចាំបាច់ពិចារណាពីទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទម្រង់នៃការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ។

**តាមពិត សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមានលក្ខណៈមិនច្បាស់លាស់**

លក្ខណៈដាច់ដោយឡែករបស់ អ.វ.ត.ក ដែលជំរុញឲ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ក៏បណ្តាលឲ្យសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមានលក្ខណៈមិនច្បាស់លាស់ ។ ដោយសាររចនាសម្ព័ន្ធរួមនៃច្បាប់ ខមិនឡូ និងច្បាប់ស៊ីវិលរបស់ អ.វ.ត.ក សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះអាចអនុវត្តបានត្រឹមតែដំណាក់កាលមុនអង្គសេចក្តីតែប៉ុណ្ណោះ ។ ហើយសេចក្តីសម្រេចនេះមិនមានជាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះសាលាដំបូងនោះទេ ។ សេចក្តីសម្រេចនេះមានជាប់ពាក់ព័ន្ធទៅនឹងការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត និងដាក់កម្រិតលើវិសាលភាពនៃការធ្វើសកម្មភាពដែលសហចៅក្រមស៊ើបអង្កេតមាននៅក្នុងដំណើរការស៊ើបអង្កេតរបស់ខ្លួន ។ ដោយហេតុនេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវទៅតាមកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងនាមជាអ្នកត្រួសត្រាយផ្លូវ សម្រាប់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅក្នុងដំណើរការស៊ើបអង្កេត ។ ជាមួយគ្នានេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក៏ធ្វើការដាក់កម្រិតលើអំណាចស៊ើបអង្កេត និងបន្ទុកការងាររបស់សហចៅក្រមស៊ើបអង្កេតដែរ ។ យ៉ាងណាមិញ ការដាក់កម្រិតនេះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងបាន នៅពេលដែលសំណុំរឿងត្រូវបានដាក់បញ្ជូនដល់តុលាការ ។ អង្គជំនុំជម្រះសាលាដំបូងក៏អាចងាកចេញពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំងស្រុងបាន ហើយក៏អាចចេញសេចក្តីសម្រេចថា ទម្រង់ទ្រឹស្តីសហឧក្រិដ្ឋកម្មទាំងបីអាចយកមកអនុវត្ត ឬមិនអាចយកមកអនុវត្តបានទៀតផង ។

សេចក្តីសម្រេចនេះបណ្តាលឲ្យមានការអសមត្ថភាពដែលមិនទាន់អាចដោះស្រាយបាន រហូតដល់អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះជាមុនសិន ។ អង្គជំនុំជម្រះ

សាលាដំបូងគួរតែអនុម័តទម្រង់ទាំងអស់ ឬទម្រង់ខ្លះនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ប៉ុន្តែសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះផ្តល់ជាយន្តការដ៏សំខាន់មួយ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងអាចអនុម័តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះបាន ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺជាសេចក្តីសម្រេចមួយស្តីពីការឆ្លុះបញ្ចាំងឲ្យឃើញពីគោលបំណងសំខាន់ៗទាំងអស់ ។ ការដែលតុលាការសម្រេចអនុម័តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះ នឹងជួយជំនះនូវឧបសគ្គដែលប្រឆាំងនឹងការប្រើប្រាស់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមដែលកើតមាននាពេលថ្មីៗនេះ ។ បន្ថែមលើនេះ ក្នុងចំណោមបញ្ហាដែលមានចំពោះមុខតុលាការពិសេសទាំងអស់ បញ្ហាដែលមានចំពោះមុខ អ.វ.ត.ក បានឆ្លុះបញ្ចាំងឲ្យឃើញពីឧបសគ្គដ៏ធំមួយដែលចោទសួរថា តើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះត្រូវបានចាត់ទុកជាច្បាប់ទម្លាប់អន្តរជាតិតាំងពីពេលណាមក ។ យ៉ាងណាមិញ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជំរុញឲ្យមានការជឿជាក់ថា ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមត្រូវបានចាប់ផ្តើមកកើតដំបូងនៅទសវត្សរ៍ទី៤០ ។ ដូច្នេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះផ្តល់ជាសេចក្តីអនុញ្ញាតបឋម សម្រាប់ការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅឯ អ.វ.ត.ក ប្រសិនបើតុលាការសម្រេចជ្រើសរើសធ្វើដូច្នេះ ។

## សេចក្តីបញ្ចប់

អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក គួរតែធ្វើការពិចារណាហេតុផលទាំងអស់ខាងលើនេះ នៅពេលខ្លួនប្រឈមមុខនឹងការចោទសួរថា តើអង្គជំនុំជម្រះគួរតែអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនេះដែរ ឬទេ ឬអនុវត្តទ្រឹស្តីនេះដោយរបៀបណា ។ យុត្តិសាស្ត្រដើមរបស់តុលាការក្រោយសង្គ្រាមលោកលើកទី២ យុត្តិសាស្ត្រទាក់ទិននឹងទ្រឹស្តីសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ និងគោលដៅ និងគោលបំណងរបស់ អ.វ.ត.ក ទាំងអស់នេះបញ្ជាក់ឲ្យឃើញថា វាមានលក្ខណៈត្រឹមត្រូវនិងសមហេតុផលក្នុងការសម្រេចអនុម័តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមសម្រាប់រឿងក្តីដែលមានចំពោះមុខ អ.វ.ត.ក ។ ការធ្វើឲ្យបុគ្គលម្នាក់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួនគឺជារឿងលំបាក ។ ម្យ៉ាងវិញទៀត កិច្ចខំប្រឹងប្រែងជំរុញឲ្យមានការទទួលខុសត្រូវនេះ មិនមែនកើតចេញជាលើកដំបូងពីសំណាក់អង្គបុរេជំនុំជម្រះនោះទេ ។ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬតុលាការពិសេសសម្រាប់ប្រទេស សៀរ៉ា ឡេអូន ក៏មិនមែនជាប្រទេសដំបូងគេបង្អស់ ដែលព្យាយាមស្វែងរកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មសាហាវយង់ឃ្នងដែលជនជាប់ចោទទាំងអស់នេះបានប្រព្រឹត្តដែរ ។ បណ្តឹងស្តីពីឧក្រិដ្ឋកម្មសាហាវយង់ឃ្នងបានរីករាលដាលចាប់តាំងពីទសវត្សរ៍ទី៤០ ដោយបង្កើតឲ្យមានជាតុលាការក្រោយសង្គ្រាមលោកលើកទី២ ។ ដូចដែលតុលាការនេះបានស្វែងយល់ឃើញ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺ ជាមធ្យោបាយសម្រេចមួយក្នុងការ

នាំជនដែលទទួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិមកកាត់ទោស ។ សង្គ្រាមដែលកើតមាននៅប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥-១៩៧៩ បណ្តាលឲ្យប្រជាជនចំនួន១,៧លាននាក់បាត់បង់ជីវិត ។ អ.វ.ត.ក ត្រូវការមធ្យោបាយច្រើនតាមតែអាចមានតាមផ្លូវច្បាប់ ដើម្បីធានាថាជនដែលមានពិរុទ្ធភាពខ្ពស់ត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ ដូចដែលបានលើកហេតុផលខាងលើ ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងអស់នោះ ។